## អង្គរបុរី
### សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ មុនព្រះពុទ្ធត្រាស់ដឹង ព្រះពោធិសត្វព្រះសិទ្ធត្ថបានផ្ចាញ់នូវមារព្រមទាំងសេនា ទីបំផុតព្រះអង្គមានជ័យជំនះបានត្រាស់ជាព្រះពុទ្ធ តើមារដែលព្រះអង្គបានផ្ចាញ់នោះ បានដល់អ្វី ?

website : www.hoksavann.org

ថ្ងៃទី៥ ឧសភា ២០០៧



មារដែលព្រះពោធិសត្វបានផ្ចាញ់មុនត្រាស់ដឹងនោះមានពីរប្រភេទគឺ មារក្តៅមួយ ត្រជាក់មួយ ។ មារក្តៅតាមការនិទានក្នុងពុទ្ធប្រវត្តិថា បន្ទាប់ពីព្រះពោធិសត្វព្រះសិទ្ធត្ថបានសោយមធុបាយាស ដែលនាងសុជាតាបានថ្វាយមក ព្រះអង្គបានពិចារណាឃើញថា នៅយប់នោះ ព្រះអង្គពិតជាបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្នុងលោក ។ បានជាព្រះអង្គហ៊ានសន្និដ្ឋានទុកជាដូច្នេះ ព្រះអង្គបានរកឃើញមាគ៌ាជាផ្លូវត្រាស់ដឹងនៅពេលនោះឯង ។ ព្រះអង្គបានគត់ព្រះភ្នែនពែនព្រះបាទនៅក្រោមដើមពោធិព្រឹក្ស ដោយតាំងព្រះទ័យប្រតិបត្តិតាមសីលសមាជបញ្ញា ដែលជាមគ្គប្រកបដោយអង្គ៨ ជាផ្លូវនៃការត្រាស់ដឹង ។ ពេលនោះឯងមានពួកមារាធិរាជ ព្រមទាំងសេនាបានលើកទ័ពច្រើនមីរដេរដាស ស្ថិតនៅពីមុខពីក្រោយ ពីចំហៀង ខ្លះហោះហើរដើរលើអាកាស ខ្លះជិះសត្វពាហនៈផ្សេងៗ ដែលមានដៃកាន់ដាវលំពែងធ្នូស្នា បញ្ចេញឫទ្ធិរបស់ខ្លួនកក្រើកព្រះធរណី នាំគ្នាមកកំរាមកំហែងព្រះពោធិសត្វ ដែលកំពុងគង់ចំរើនធម៌យ៉ាងស្ងៀមស្ងាត់ ។ គោលបំណងនៃពួកមារ ដែលមកច្បាំងនឹងព្រះពោធិសត្វពេលនោះ គឺមិនចង់ឲ្យព្រះពោធិសត្វត្រាស់ជាព្រះពុទ្ធកន្លងវិស័យរបស់ខ្លួន ពុំមែនត្រឹមតែដណ្តើមបល្ល័ង្កដែលព្រះអង្គកំពុងគង់នោះទេ ។ ឯព្រះពោធិសត្វបានផ្ចាញ់វិញដោយបារមីធម៌ ដែលព្រះអង្គបានកសាងជាច្រើនជាតិមកហើយ បំណងត្រាស់ជាព្រះពុទ្ធដើម្បី

ចម្លងសត្វ ឲ្យបានសំរេចព្រះនិព្វាន ជាការរំលត់ទុក្ខ ។ ទីបំផុតពួកមារព្រមទាំងសេនា បានត្រូវបរាជ័យដោយបារមីរបស់ព្រះអង្គ មានទានបារមីជាដើម ។ បន្ទាប់ពីសង្គ្រាមក្តៅបានផុតរលត់ទៅ ពួកមារបានគិតថា នៅមានមធ្យោបាយមួយទៀត ដើម្បីយកជ័យជំនះពីព្រះសិទ្ធត្ថពោធិសត្វ គឺសង្គ្រាមត្រជាក់ ។ មធ្យោបាយទី២នេះ គឺពួកមារបានបញ្ចេញបុត្រីរបស់ខ្លួន៣នាក់ ដែលមានរូបលោមពណ៌ដ៏ល្អឆើតឆាយ លើសស្ត្រីក្នុងសួគ៌ា គឺព្រះនាងរាគី ព្រះនាងអរតី និងព្រះនាងតណ្ហា ដោយមារមានគំនិតថា បើព្រះពោធិសត្វមានព្រះទ័យស្រឡាញ់ជាប់ចិត្តនឹងបុត្រីខ្លួនក្នុងផ្លូវកាមគុណ គឺរូបសម្លេងក្លិនរសនិងសម្ផស្សហើយ នឹងមិនបានត្រាស់ជាព្រះពុទ្ធឡើយ ពេលនោះខ្លួនបានទទួលជ័យជំនះ ។ បុត្រីរបស់ពួកមារទាំងបីនាក់ក៏បានបញ្ចេញជំនាញការរបស់ខ្លួន ដោយបច្ចេកទេសខ្ពស់ តាមការបង្ហាត់បង្រៀនរបស់បិតាខ្លួន ដោយការរាំច្រៀងកាច់ក្បាច់យ៉ាងទន់ភ្លន់ ប្រើអស់ចំណេះអស់សមត្ថភាពដែលខ្លួនមាន ក៏ពុំអាចធ្វើឲ្យព្រះទ័យរបស់ព្រះអង្គកំរើកទៅរកកាមគុណទាំងនោះឡើយ ។ សង្គ្រាមត្រជាក់ទី២នេះ ពួកមារបានត្រូវបរាជ័យទៀត ហើយសុំចុះចាញ់ រួចក៏បាត់ខ្លួនអស់ទៅ ។ ពេលនោះហើយដែលព្រះពោធិសត្វសិទ្ធត្ថបានឈ្នះពួកមារដោយដាច់ខាត ហើយការត្រាស់ដឹងជាសម្មាសម្ពោធិញ្ញាណក៏កើតឡើងក្នុងពេលនោះឯង ក្នុងថ្ងៃ១៤កើតខែពិសាខណោលភ្លឺស្រាងៗ ។ នៅពេលនោះ ពពួកទេវតាបានជ្រាបពីការត្រាស់ដឹងនេះ ក៏ថ្វាយព្រះពរស័ព្ទសាធុការចំពោះព្រះពុទ្ធឈ្នះមារ ។ ផ្កាឈើគ្រប់ធុនក៏បានរីកស្គុះស្គាយជាសញ្ញានៃការត្រាស់ដឹងរបស់ព្រះអង្គ ។

ពួកមារទាំងពីរប្រភេទដែលបានពោលមកនេះ បើនិយាយតាមផ្លូវចិត្តវិញ គឺពួកមារដែលច្បាំងនឹងព្រះពោធិសត្វ ដោយប្រើយុទ្ធភណ្ឌផ្សេងៗនោះ ជានិមិត្តរូបនៃទោសៈជាសង្គ្រាមក្តៅដែលស្ថិតនៅក្នុងព្រះទ័យព្រះពោធិសត្វព្រះសិទ្ធត្ថពេលមិនទាន់បានត្រាស់ដឹង ព្រោះមនុស្សដែលប្រើធម៌ហឹង្សាច្បាំងកាប់សម្លាប់គ្នា ដោយសារទោសចិត្ត ។ ឯបុត្រីរបស់មារទាំងបី គឺនាងរាគី នាងអរតី និងនាងតណ្ហា ជានិមិត្តរូបនៃលោភៈ ឬរាគៈ ជាសង្គ្រាមត្រជាក់ ដែលស្ថិតនៅក្នុងព្រះទ័យព្រះពោធិសត្វសិទ្ធត្ថ ពេលមិនទាន់បានត្រាស់ជាព្រះពុទ្ធ ព្រោះមនុស្សដែលជាប់ចិត្តក្នុងកាមគុណ៥មានរូបជាដើមដោយធម៌រាគៈ ។ មធ្យោបាយយកឈ្នះចាញ់គ្នាក្នុងផ្លូវអាណាចក្រ គេប្រើវិធីទាំងពីរប្រភេទ គឺពិធីល្បួងលោមផ្លូវចិត្តជាសង្គ្រាមត្រជាក់ គឺការផ្សាយមនោគមវិជ្ជា បញ្ចុះបញ្ចូលទាញមនុស្សឲ្យជឿនូវជំនឿរបស់ខ្លួន ។ វិធីមួយទៀត គឺមធ្យោបាយក្តៅគំរាមកំហែងដោយសំដីរហូតប្រើអាវុធយុទ្ធភ័ណ្ឌ ដើម្បីឲ្យខ្លាចហើយចុះចាញ់ វិធីនេះជាមធ្យោបាយក្រៅច្បាប់ ភាគច្រើនអ្នកមានអំណាចប្រើមកលើអ្នកទន់ខ្សោយគ្មានអំណាច ។ អកុសលមូលទាំង៣គឺ លោភៈ ទោសៈ មោហៈ ជាឫសគល់នៃនាំឲ្យបុគ្គលសាងបាបកម្ម ដែលមានទោសធ្ងន់ស្រាលជាងគ្នា គឺលោភៈមានទោសស្រាលតែពិបាកលះ, ទោសៈមានទោសធ្ងន់តែស្រណុក ចំណែកមោហៈមាន

ទោសធ្ងន់ផងពិបាកលះផង ។ អកុសលមូលទាំងបីនេះ ព្រះពោធិសត្វព្រះសិទ្ធត្ថលះបានទាំងបីដោយដាច់ខាត ទើបព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ។ លោភៈ និងរាគៈការជាប់ចិត្តទៅលើកាមគុណ៥មានរូបជាដើម ពិបាកលះណាស់ ។ តាមប្រវត្តិសាស្ត្រ អ្នកកាន់អំណាចរដ្ឋខ្លះចាញ់សង្គ្រាម ដោយសារគេបញ្ចូលស្រីមកធ្វើជានុយ ។ ក៏ដូចគ្នានឹងប្រទេសកម្ពុជា បានបាត់បង់ទឹកដីក្នុងសម័យកាលខ្លះ ក៏ដោយសារតែអ្នកដឹកនាំខ្មែរសប្បាយភ្លេចខ្លួននឹងស្រី ដែលគេយកមកឲ្យជានុយដូចនេះដែរ ។៚

❉ ❉

❉